# ផលប៉ះពាល់របស់ RCEP មកលើស្បៀងអាហារ និង កសិករ

កិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចថ្នាក់តំបន់ទូលំទូលាយ (RCEP) គឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មប្រចាំតំបន់ដ៏ធំមួយត្រូវបានចរចារដោយ១៦ប្រទេសនៅក្នុងទូទាំងអាស៊ីប៉ាស៊ីហ្វិក៖ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី ព្រុយណេ វៀតណាម ឡាវ ភូមា កម្ពុជា ចិន ជប៉ុន កូរ៉េខាងត្បូង ឥណ្ឌា អូស្ត្រាលី និងញូហ្សេលេន។ បើសិនជាគេអនុម័ត RCEP នោះវានឹងគ្របដណ្តប់លើចំនួនប្រជាជនពាក់កណ្តាលនៃពិភពលោក រួមមាន៤២០លានគ្រួសារកសិករខ្នាតតូចដែលជាអ្នកផលិត ៨០% នៃស្បៀងអាហារសម្រាប់តំបន់។ តើកិច្ចព្រមព្រៀងនេះ មានន័យយ៉ាងដូចម្តេចចំពោះស្បៀងអាហារ និង កសិករក្នុងតំបន់?

## ដីធ្លីនឹងត្រូវគេដណ្តើមយក



• នៅក្នុងប្រទេសសមាជិក RCEP ដីកសិកម្មចំនួន៩,៦ លានហិកតាត្រូវបានប្តូរអ្នកកាន់កាប់តាំងពីឆ្នាំ២០០៨។ ជំពូកចំនួន២នៅក្នុងRCEP មានផលប៉ះពាល់ខ្លាំងមកលើការកាន់កាប់ដីធ្លី។

• ជំពូកដែលបានបែកធ្លាយ ស្តីពីវិនិយោគ ធ្វើការកំណត់ច្បាប់អោយរដ្ឋាភិបាលត្រូវតែផ្តល់សិទ្ធិអោយអ្នកវិនិយោគដែលមកពីប្រទេសសមាជិកRCEPផ្សេងទៀតមានសិទ្ធិទិញដីកសិកម្មដូចអ្នកវិនិយោគក្នុងស្រុក។ ប្រទេសសមាជិកRCEP ភាគច្រើន មិនអនុញ្ញាតអោយបរទេសទិញដីកសិកម្មនោះទេ។

• ជំពូកស្តីពីសេវាកម្ម អាចអនុញ្ញាតអោយជនបរទេសធ្វើជាម្ចាស់កម្មសិទ្ធិលើដីកសិកម្មដើម្បីដំណើរការគ្រប់អាជីវកម្មពាក់ពន្ធ័នឹងការផ្តល់សេវាកម្ម។



## កសិករផលិតទឹកដោះគោ និងកសិករខ្នាតតូចផ្សេងទៀតនិងបាត់បង់មុខរបរ

• RCEP នឹងបំផ្លាញកសិករ អ្នកផលិតខ្នាតតូច ដោយសារតែការបើកទីផ្សារអោយមានការប្រគួតប្រជែងដោយគ្មានយុត្តិធម៌ជាមួយនឹងអ្នកផលិតដែលទទួលបានការគាំទ្រពីរដ្ឋរបស់ពួកគេ មកពីជប៉ុន អូស្ត្រាលី និងញូហ្សេលេន។ កសិករចិញ្ចឹមសត្វនិងផលិតទឹកដោះគោប្រមាណជា ១០០លាននាក់នៅឥណ្ឌា ទទួលរងផលប៉ះពាល់។

• ក្រុមហ៊ុនផលិតទឹកដោះគោដ៏ធំរបស់ញូហ្សេលេន ហ្វុនតេរ៉ា ជាក្រុមហ៊ុនដែលនាំចេញផលិតផលទឹកដោះគោដ៏ធំបំផុតនៅលើពិភពលោក មានគោលបំណងប្រើប្រាស់ RCEP ដើម្បីចូលទៅក្នុងប្រទេសឥណ្ឌាដែលរដ្ឋាភិបាលកន្លងមកបរាជ័យក្នុងការធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី។ ប្រជាជនខ្លាចកសិករផលិតទឹកដោះគោនៅឥណ្ឌានិងធ្វើការបម្រើអោយហ្វុនតេរ៉ា ឬ ប្រឈមបាត់បង់មុខរបរ។

• RCEP នឹងលើកទឹកចិត្តអោយមានបង្កើតតំបន់ផលិតអាហារដ៏ធំ ដោយផ្តោតខ្លាំងទៅលើប្រទេសជាអ្នកផ្គត់ផ្គង់ដូចជា ជប៉ុន និងអូស្ត្រាលី ដែលមានស្តង់ដាអាហារសុវត្ថិភាព ហើយផលិតកម្ម កាកែច្នៃអាហារខ្នាតតូចមិនអាចប្រគួតប្រជែងបាន។ ប្រពន្ធ័ផលិតកម្មអាហារដែលមានលក្ខណៈបច្ចេកទេសខ្ពស់បែបនេះ បានផាត់ចេញនូវអ្នកផលិតនិងអាជីវកម្មកែច្នៃអាហារបែបគ្រួសារ និង បណ្តេញពួកគេចេញពីទីផ្សារ និង ការគ្រប់គ្រងដីធ្លី។

## គ្រាប់ពូជនឹងត្រូវគ្រប់គ្រងដោយឯកជន ហើយគ្រាប់ពូជ GMO នឹងរីកសាយ

• បច្ចុប្បន្ន ឧស្សាហកម្មគ្រាប់ពូជពិភពលោកកំពុងប្រមូលផ្តុំគ្នា។ ក្រុមហ៊ុនធំចំនួន៣ ក្តោបក្តាប់ច្រើនជាង៦០%នៃអាជីវកម្មផ្នែកលក់នៃពិភពលោក។

• ជំពូកក្នុងសេចក្តីព្រៀងRCEPដែលបែកធ្លាយ ស្តីពីកម្មសិទ្ធិបញ្ញា ជម្រុញអោយរដ្ឋសមាជិកRCEP អនុម័ត "UPOV 1991" ជាសន្ធិសញ្ញាអន្តរជាតិដែលកសិកមិនត្រូវបានអនុញ្ញាតអោយសន្សំទុកគ្រាប់ពូជដែលជាប់ប៉ាតង់។ ក្នុងករណីមានការអនុញ្ញាតិ កសិករត្រូវបង់លុយទៅអោយក្រុមហ៊ុនគ្រាប់ពូជចំពោះពូជដែលបានសន្សំ ហើយតម្លៃនោះគឺ១០ទៅ៤០%ថ្លៃជាងពូជដែលដាក់លក់នៅលើទីផ្សារ។ នៅអាស៊ីការអនុវត្តនេះ អាចធ្វើអោយតម្លៃក្នុងស្រុកកើនឡើងពី២០០%ទៅ៦០០%។

• បើសិនជាការចរចារRCEPកាន់តែដូចទៅនឹងអ្វីដែលមាននៅក្នុង TPP នោះវានឹងរឹតតែអាក្រក់។ TPP តម្រូវអោយរដ្ឋផ្តល់ការការពារប៉ាតង់ទៅលើការច្នៃប្រឌិត "លើរុក្ខជាតិ" សំដៅទៅដល់ ការបំលែងសេនេទិច (សែន)។



## ការលក់រាយខ្នាតធំនឹងលុបបំបាត់ទីផ្សារក្នុងស្រុក

• យោងទៅតាមសេចក្តីព្រៀងដែលបែកធ្លាយ ជំពូកស្តីពីសេវាកម្មនៅក្នុងRCEP រដ្ឋាភិបាលមិនអាចដាក់កម្រិតទៅលើដំណើរការទីផ្សារទំនើបដែលហូរចូលពីប្រទេសសមាជិកRCEPផ្សេងទៀតបានឡើយ។

• ប្រសិនបើគេធ្វើតាមអ្វីដែលមានចែងក្នុងTPP នោះ"កសិកម្មបែបបច្ចេកវិទ្យា" (ការប្រើប្រាស់កុំព្យូទ័រ និង បច្ចេកវិទ្យាក្នុងការទំនាក់ទំនងសម្រាប់គ្រប់គ្រងដំណើរការកសិដ្ឋាន) និងត្រូវដាក់នៅក្នុងRCEPដើម្បីលើកស្ទួយដល់ចង្វាក់នៃការផ្គត់ផ្គង់ និងពាណិជ្ជកម្មតាមរយៈប្រព័ន្ធអេឡិចត្រូនិក។



• កិច្ចព្រមព្រៀងពាណិជ្ជកម្ម ដាក់រដ្ឋាភិបាលអោយខុសច្បាប់ ប្រសិនបើរដ្ឋាភិបាលតម្រូវអោយក្រុមហ៊ុនអ្នកផ្គត់ផ្គង់ដូចជា អាលីបាបា ឬ អេអន ទទួលយកការចូលរួមពីអ្នកផលិតក្នុងស្រុក ឬ ទទួលទិញស្បៀងអាហារពីអ្នកផលិតក្នុងស្រុក។







## ការប្រើប្រាស់ជីគីមីកើនឡើង

• រដ្ឋមន្ត្រីពាណិជ្ជកម្មរបស់RCEP សន្យាព្រមកាត់បន្ថយពន្ធគយភ្លាមៗមកត្រឹមកម្រិតសូន្យចំពោះពាណិជ្ជកម្មទៅលើទំនិញ ៦៥%។

• ចិន ទិញក្រុមហ៊ុន ស៊ីនជេនតា ដែលជាក្រុមហ៊ុនកសិកម្មបែបគីមីដ៏ធំមួយលំដាប់ពិភពលោក ក្តោបក្តាប់ច្រើនជាង២០%នៃទីផ្សារថ្នាំកសិកម្មពិភពលោក នេះមានន័យថា ប្រទេសចិននឹងទទួលបានចំនេញយ៉ាងសំបើមពី RCEP។ នៅក្នុងខែមករា ២០១៧ ចិនបានប្រកាសថានឹងបញ្ចប់ពន្ធគយមកលើជីនីជ្រូសែន និង ផូស្វ័រ ដើម្បីបង្កើនភាគហ៊ុនទីផ្សារនៅបរទេស។

• បើសិនជាជំពូកស្តីពីកម្មសិទ្ធិបញ្ញាដែលបានបែកធ្លាយនោះត្រូវបានអនុម័ត RCEP អាចបង្កើនការដាក់ប៉ាតង់ទៅលើជាតុចូលផ្សេងៗដូចជាថ្នាំព្យាបាលសត្វ គ្រឿងចក្រសម្រាប់កសិកម្ម ផលិតផលសារពាង្គកាយតូចៗ និងសារធាតុគីមីកសិកម្ម និង ពន្យារយៈពេលប៉ាតង់ដែលធ្វើអោយផលិតផលទាំងនោះកាន់តែថ្លៃ។

ហ្គ្រេន (GRAIN) សូមអរគុណដល់វេទិកាអាស៊ីប៉ាស៊ីហ្វិកស្តីពី ស្ត្រី ច្បាប់ និងការអភិវឌ្ឍន៍ សម្ព័ន្ធភាពកសិករអាស៊ី និងបណ្តាញទី៣របស់ពិភពលោកសម្រាប់ការដាក់បញ្ចូលរបស់ពួកគេនៅក្នុងអត្ថបទនេះ។
https://www.grain.org/e/5741 ឯកសារបកប្រែមិនផ្លូវការដោយសកម្មភាពសង្គមដើម្បីការផ្លាស់ប្តូរ ទាញចេញពីហ្គ្រេន (GRAIN) https://www.grain.org/article/entries/5741-how-rcep-affects-food-and-farmers

## ធ្វើសកម្មភាពឥឡូវនេះ!

លទ្ធផលចេញពីការផ្លាស់ប្តូរទាំងនេះនឹងធ្វើអោយក្រុមហ៊ុនសាជីវកម្មគ្រប់គ្រងវិស័យស្បៀងអាហារនិងកសិកម្ម។ ចម្លើយសម្រាប់សកម្មភាព គឺមិនមែនការកែទម្រង់RCEPនោះទេ ប៉ុន្តែត្រូវតែបដិសេដវា ពីព្រោះវាពឹងផ្អែកនិងជម្រុញអោយអនុវត្តគម្រូកសិកម្មរបស់ក្រុមហ៊ុនសាជីវកម្ម។ ពួកយើងត្រូវការ ការអនុវត្តនូវគោលនយោបាយនិងការផ្តួចផ្តើមនានា ដែលអាចធ្វើអោយប្រព័ន្ធស្បៀងអាហារនិងកសិកម្មដឹកនាំដោយប្រជាជន មានការរីកដុះដាលឡើង។ ហើយនៅពេលនោះហើយដែលគោលនយោបាយពាណិជ្ជកម្ម គឺត្រូវធ្វើឡើងដើម្បីតម្រូវ បម្រើអោយប្រព័ន្ធនេះ មិនមែនប្រព័ន្ធផ្សេងនោះទេ។

• ស្វែងរកព័ត៌មានថ្មី និងបង្កើតការពិភាក្សាដេញដោលអំពី RCEPនៅក្នុងសហគមន៍របស់អ្នក។ ប្រភពមួយដែលអ្នកអាចស្វែងរកព័ត៌មានបានគឺគេហទំព័រមួយhttp://www.bilaterals.org/rcep.

• គាំទ្រសេចក្តីអំពាវនាវពីប្រជាជនឲ្យបញ្ឈប់RCEP និងប្រយុទ្ធដើម្បីប្រព័ន្ធពាណិជ្ជកម្មបម្រើប្រជាជនដែលឆ្លើយតបតម្រូវការប្រជាជន មិនមែនពួកអភិជន សាជីវកម្ម។ សូមទំនាក់ទំនងក្រុមនានាក្នុងប្រទេសរបស់អ្នកដែលបានចុះហត្ថលេខាលើសេចក្តីអំពាវនាវ និងចូលរួមជាកម្លាំង

• ចូលរួមការប្រជុំRCEP។ សូមទាមទារឲ្យមានការបង្ហាញពីខ្លឹមសារចរចាជាសាធារណៈដើម្បីជួយដល់ការវិភាគបានប្រសើរជាងមុន និងកសាងចំនេះដឹងពីផលប៉ះពាល់នៃកិច្ចព្រមព្រៀងលើជីវភាពរស់នៅរបស់ប្រជាជននៅក្នុងប្រទេសជាសមាជិកRCEP។ សូមលើកឡើងពីក្តីកង្វល់របស់អ្នក ដូចដែលក្រុមនានាបានធ្វើនៅក្នុងការប្រជុំផ្សេងៗកន្លងមកនៅទីក្រុងផើស ទីក្រុងចាកាតា កូបិ និងម៉ានីល។ កិច្ចប្រជុំបន្ទាប់នឹងធ្វើនៅទីក្រុង ហ៊ីដឺរ៉ាបាត (នៅខែកក្កដាឆ្នាំ២០១៧) និងទីក្រុងសេអ៊ូល(ពេលក្រោយទៀតក្នុងឆ្នាំនេះ)។

• ចូលរួមយុទ្ធនាការប្រជាជនក្នុងទ្រង់ទ្រាយធំថ្នាក់តំបន់អំពីRCEP និងយុត្តិធម៌ក្នុងពាណិជ្ជកម្ម ហើយចូលរួមក្នុងការប្រមូលផ្តុំគ្នាដូចជានៅថ្ងៃធ្វើសកម្មភាពថ្នាក់តំបន់

• បន្តតាមដានតាមគេហទំព័រ http://rceplegal.wordpress.com/ និង http://keionline.org/ និង http://www/bilaterals.org/rcep-leaks ដើម្បីទទួលបានខ្លឹមសារបែកធ្លាយ និងការវិភាគផ្សេងៗពីជំពូកនៅក្នុងRCEP